ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
NATIONAL COMMERCIAL ARBITRATION CENTER

លេខ: ១១៣ / ម.ជ.ម./១៨

*រាជធានីភ្នំពេញ* ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨

**សេចក្តីសម្រេច**
**ស្តីពី**
**ការតែងតាំងគណៈកម្មាធិការអប់រំ និងបណ្តុះបណ្តាល**

**ប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា ៥២នៃអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ០៥១៨ MOC/SM ២០១៣ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាប្រតិបត្តិរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- បានឃើញបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិនាសម័យប្រជុំថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨
- យោងតាមការចាំបាច់នៃការងារ

**សម្រេច**

**ប្រការ ១**.- ត្រូវបានតែងតាំងប្រធាន អនុប្រធាននិងសមាជិករបស់គណៈកម្មាធិការអប់រំនិងបណ្តុះបណ្តាលនៃមជ្ឈមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ៖

| | |
|---|---|
| ១- លោកមជ្ឈត្តករ **ប៉ា ចន្ទនគា** | ប្រធាន |
| ២- លោកមជ្ឈត្តករ **កុយ នាម** | អនុប្រធានទី១ |
| ៣- លោកមជ្ឈត្តករ **តិន សុខត្ថិ** | អនុប្រធានទី២ |
| ៤- លោកមជ្ឈត្តករ **អ៊ឹង សុភ័ក្ត្រ** | សមាជិក |

៥- លោកមជ្ឈត្តករ **សេង សុខឃីម** សមាជិក

៦- លោកមជ្ឈត្តករ **ខាន់ សេរីវុទ្ធី** សមាជិក

៧- លោកមជ្ឈត្តករ **អ៊ុច វុទ្ធី** សមាជិក

៨- លោកមជ្ឈត្តករ **ណុប សុខា** សមាជិក

៩- លោកមជ្ឈត្តករ **ទេព្យ មុនាថ** សមាជិក

**ប្រការ ២.**- ប្រធាន ម.ជ.ម. ឬ បុគ្គលដែលចាត់តាំងដោយប្រធាន ម.ជ.ម. ឬ ប្រធានគណៈកម្មាធិការ ជាប្រធានអង្គប្រជុំ ជាអ្នកកោះប្រជុំ ដឹកនាំអង្គប្រជុំ និងសម្របសម្រួលអង្គប្រជុំ។ អនុប្រធាន ជួយការងារប្រធានតាមការចាត់តាំង។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានទី១ ត្រូវជំនួស ប្រធាន។ ប្រធានអង្គប្រជុំ អាចចាត់តាំងសមាជិកណាម្នាក់ឲ្យធ្វើជាលេខាកត់ត្រា។ តាមការ ចាំបាច់ លេខាធិការដ្ឋានអាចផ្តល់បុគ្គលិករបស់ខ្លួនសម្រាប់ជួយគណៈកម្មាធិការ ប្រសិនបើ មានការស្នើសុំ។

កូរ៉ុមប្រជុំអាចប្រព្រឹត្តិទៅបាន លុះត្រាតែមានវត្តមានភាគច្រើននៃសមាជិករបស់គណៈកម្មាធិ-ការ។

វត្តមានរបស់ប្រធាន ម.ជ.ម. មិនត្រូវបានរាប់សម្រាប់គិតកូរ៉ុមប្រជុំទេ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការ ត្រូវធ្វើឡើងដោយសំឡេងភាគច្រើននៃសមាជិកដែល មានវត្តមានទាំងអស់រួមទាំងសិទ្ធិប្រទាន។ សមាជិក ដែលអវត្តមានអាចធ្វើសិទ្ធិប្រទានបាន។ សមាជិកម្នាក់អាចទទួលសិទ្ធិប្រទានបានតែមួយប៉ុណ្ណោះ។

សម័យប្រជុំនៃគណៈកម្មាធិការត្រូវធ្វើឡើងនៅទីស្នាក់ការរបស់ម.ជ.ម. ឬនៅកន្លែងដទៃទៀត ដូចមានបញ្ជាក់ក្នុងលិខិតអញ្ជើញ។ លិខិតអញ្ជើញត្រូវចែងពីកាលបរិច្ឆេទ របៀបវារៈ និង ទីកន្លែងនៃការប្រជុំ និងផ្ញើជូនយ៉ាងយូរ ៣ ថ្ងៃ មុនថ្ងៃប្រជុំ។

**ប្រការ ៣.**- គណៈកម្មាធិការអប់រំ និងបណ្តុះបណ្តាលត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

ក- ផ្តល់យោបល់ជូនក្រុមប្រឹក្សាប្រតិបត្តិពាក់ព័ន្ធនឹងការអភិវឌ្ឍគោលនយោបាយទាក់ទង នឹងការអប់រំ និងកម្មវិធីបណ្តុះបណ្តាល រួមទាំងការអភិវឌ្ឍវិជ្ជាជីវៈដំបូង និងបន្តសម្រាប់ សមាជិក ម.ជ.ម. និងបុគ្គលដែលមានបំណងអនុវត្តវិជ្ជាជីវៈជាមជ្ឈត្តករស្របតាមច្បាប់ ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម អនុក្រឹត្យលេខ១២៥ និងវិធានជាធរមានផ្សេងៗ។

ខ- ផ្តល់យោបល់ជូនក្រុមប្រឹក្សាប្រតិបត្តិពាក់ព័ន្ធនឹងការទទួលស្គាល់ស្ថាប័នវិជ្ជាជីវៈមជ្ឈត្តការ ផ្នែកពាណិជ្ជកម្ម កម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាលនានា។

គ- សិក្សាស្រាវជ្រាវច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

ឃ- ធ្វើការវិភាគនូវខ្លឹមសារច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមជ្ឈត្តការផ្នែក ពាណិជ្ជកម្ម ដើម្បីដាក់ជូនក្រុមប្រឹក្សាប្រតិបត្តិពិចារណា និងសម្រេច។

ង- ពិភាក្សារកចម្លើយ ដើម្បីឆ្លើយតបនឹងចម្ងល់នានារបស់មជ្ឈត្តករ និងសាធារណៈជន ពាក់ព័ន្ធនឹងខ្លឹមសាច្បាប់ និងវិធាននានាក្នុងវិស័មជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

ច- ពិភាក្សាពីប្រធានបទ និងសំណួរចម្លើយដើម្បីចូលរួមការអប់រំផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅតាមកម្មវិធី និងតាមបណ្តាញផ្សព្វផ្សាយនានា។

ឆ- ភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់ប្រធាន ម.ជ.ម.។

**ប្រការ ៤**.- អាណត្តិរបស់សមាជិករបស់គណៈកម្មាធិការមានរយៈពេល ៣(បី)ឆ្នាំ។ សមាជិកមិនអាចបម្រើការលើសពី ២(ពីរ) អាណត្តិជាប់ៗគ្នាឡើយ។

ក្រុមប្រឹក្សាប្រតិបត្តិអាចដកសមាជិកណាម្នាក់ចេញពីគណៈកម្មាធិការ យោងតាមយោបល់របស់គណៈកម្មាធិការវិន័យដោយមូលហេតុណាមួយ ជាពិសេសពាក់ព័ន្ធនឹងភាពសុចរិតនៃសកម្មភាពរបស់សមាជិក ក្នុងតួនាទីជាសមាជិកនៃគណៈកម្មាធិការ។

ប្រសិនបើសមាជិករបស់គណៈកម្មាធិការ បានបាត់បង់តំណែងរបស់ខ្លួន ក្រុមប្រឹក្សាប្រតិបត្តិត្រូវតែងតាំងសមាជិកថ្មីក្នុងអំឡុងពេល ៣០(សាមសិប) ថ្ងៃប្រតិទិន ចាប់ពីកាលបរិច្ឆេទដែលសមាជិកត្រូវបានបាត់បង់តំណែង។

**ប្រការ ៥**.- សមាជិកគណៈកម្មាធិការមិនត្រូវទទួលបានប្រាក់ឈ្នួលឡើយ ប៉ុន្តែអាចទទួលបានប្រាក់ឧបត្ថម្ភ ឬការទូទាត់សងវិញចំពោះការចំណាយចាំបាច់នានាដែលបានធ្វើស្របតាមវិធានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

**ប្រការ ៦**.- ក្រុមប្រឹក្សាប្រតិបត្តិត្រូវកំណត់វិធានបន្ថែមពាក់ព័ន្ធនឹងការប្រតិបត្តិ និងនីតិវិធីសម្រាប់ធ្វើការរបស់គណៈកម្មាធិការ។

**ប្រការ ៧**.- គណៈកម្មាធិការត្រូវទទួលខុសត្រូវចំពោះមុខប្រធានរបស់ ម.ជ.ម. និងក្រុមប្រឹក្សាប្រតិបត្តិរបស់ ម.ជ.ម. លើរាល់សកម្មភាព និងលទ្ធផលការងាររបស់ខ្លួន។

**ប្រការ ៨**.-បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩**.- អគ្គលេខាធិការ ហេរញ្ញិក និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួន។

**ប្រធាន**

**ចម្លងជូន:**

- ក្រុមប្រឹក្សាប្រតិបត្តិ
  "ដើម្បីជ្រាប"
- ដូចប្រការ ៩
- ឯកសារ-កាលប្បវត្តិ

NATIONAL COMMERCIAL ARBITRATION CENTRE

មជ្ឈត្តការរស់ មុជិដ្ឋ: